ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

ឆ្នាំទី២២ លេខ៣៧        ត្រីមាសទី០២ ឆ្នាំ២០២២

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៨-៨-២០២២ -ព្រះរាជក្រម នស/រកម/០៨២២/០១០ ស្ដីពី ការប្រកាសឱ្យប្រើច្បាប់ ស្ដីពី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ៤៤៦៩


### ២~ព្រះរាជក្រឹត្យ


៤-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ូ យូវឈីង** (SU YOUQING) ជនជាតិចិន សញ្ជាតិចិន ៤៤៩៦

៤-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦២ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ចាង ឈីចៀង** (ZHANG, QIJIANG) ជនជាតិចិន សញ្ជាតិចិន ៤៤៩៧

៤-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦៣ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ូ ស៊ាវតុង** (XU, XIAO-DONG) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៤៤៩៨

៤-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦៤ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **លី ឈុនឡុង** (LEE CHUNLONG) ជនជាតិចិន Surinaamse សញ្ជាតិ Surinaamse ៤៤៩៩

៤-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦៥ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឈិន ភីងហ្គាន** (CHEN PINGAN) ជនជាតិចិន Surinaamse សញ្ជាតិ Surinaamse ៤៥០០

៤-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦៦ ស្ដីពី ការតែងតាំងឯកឧត្តម **លាង សួគ៌** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់ចិរវេលាដែលនៅសល់ ក្នុងអាណត្តិជំនួសឯកឧត្តម **អ៊ុំ សារិទ្ធ** សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលបានទទួលមរណភាព ៤៥០១

៤-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦៧ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈជាទីប្រឹក្សារបស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ២ រូប ៤៥០២

៦-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសដល់សប្បុរសជន នៃខេត្តកំពង់ចាម ៥ រូប ៤៥០៣

៦-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៦៩ ស្ដីពី ការផ្ដល់គោរមងារលោក **យក់ ចំរើនឫទ្ធិ** ជាឧកញ៉ា ៤៥០៤

៦-៥-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧០ ស្ដីពី ការផ្ដល់គោរមងារលោក **ទិន សារឿន** ជាឧកញ៉ា ៤៥០៥

| | | |
|---|---|---|
| ៦-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧១ ស្តីពី ការតែងតាំងមុខតំណែង ជារដ្ឋលេខាធិការ និងជាអនុរដ្ឋលេខាធិការ នៃក្រសួងផែនការ ២ រូប | ៤៥០៦ |
| ៦-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧២ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ដល់ទីប្រឹក្សាក្រសួងព័ត៌មាន ដោយពុំទទួលប្រាក់បំណាច់មុខងារ ៧រូប | ៤៥០៧ |
| ៦-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៣ រូប | ៤៥០៨ |
| ៦-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **លី ជុងគឿន** (LEE JOONG KEUN) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ | ៤៥០៩ |
| ៦-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់កញ្ញា **ង្វៀន តាំង អៀនធី** (NGUYEN TANG UYEN THY) ជនជាតិវៀតណាម សញ្ជាតិវៀតណាម ដោយប្តូរឈ្មោះជា **គីម មុនី** (KIM MONY) | ៤៥១០ |
| ៦-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧៧ ស្តីពី ការតម្លើងថ្នាក់តាមវេនប្រចាំឆ្នាំ ក្នុងឋានន្តរស័ក្តិឧត្តមអភិបាល ដល់មន្ត្រីរាជការ ១៤រូប និងតម្លើងឋានន្តរស័ក្តិតាមវេនប្រចាំឆ្នាំ ដល់មន្ត្រីរាជការ ៣ រូប | ៤៥១១ |
| ៧-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧៨ ស្តីពី ការផ្តល់គោរមងារឯកឧត្តម **ហ៊ុន ណេង** ជាសម្តេច ឧត្តមទេពញាណ **ហ៊ុន ណេង** | ៤៥១៣ |
| ៩-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៧៩ ស្តីពី និយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ នៅក្រសួង ស្ថាប័ន ចំនួន ១២ ដល់មន្ត្រីរាជការ ៣៥ រូប | ៤៥១៤ |
| ៩-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៨០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ ក្រសួងសុខាភិបាល ដល់មន្ត្រីរាជការ ១៩ រូប | ៤៥២០ |
| ៩-៥-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០៥២២/៤៨១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសដល់នាយទាហាន នាយទាហានរង នៃកងយោធពលខេមរភូមិន្ទ ១០រូប | ៤៥២២ |


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ៧-៦-២០២២ | -អនុក្រឹត្យលេខ ១១៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៤៥២៣ |
| ៧-៦-២០២២ | -អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៤៥២៥ |
| ៣០-៥-២០២២ | -អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ៤៥២៧ |
| ៣០-៥-២០២២ | -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ៤៥២៨ |
| ៣០-៥-២០២២ | -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ៤៥៣០ |

១-៦-២០២២ -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៤៥៣១

១-៦-២០២២ -អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចមន្ត្រីរាជការ ៤៥៣៦

១-៦-២០២២ -អនុក្រឹត្យលេខ ៣៥៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៥៣៧

១-៦-២០២២ -អនុក្រឹត្យលេខ ៣៦០ អនក្រ.តត ស្តីពី ការលុបឈ្មោះនាយទាហាន ៤៥៣៨

១-៦-២០២២ -អនុក្រឹត្យលេខ ៣៦១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៤៥៣៩

១-៦-២០២២ -អនុក្រឹត្យលេខ ៣៦២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៤៥៤១


## III ~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


៧-៤-២០២២ -ប្រកាសអន្តរក្រសួងលេខ ២៤៨ សហវ.ប្រក ស្តីពី ការកែសម្រួលប្រភេទ និងតម្លៃសេវាសាធារណៈ ដែលស្ថិតក្នុងកម្រងសេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៤៥៤៣

៨-៤-២០២២ -ប្រកាសអន្តរក្រសួងលេខ ២៥១ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យចំណូល នៅក្រសួងទេសចរណ៍ ៤៥៤៧

២០-៤-២០២២ -ប្រកាសអន្តរក្រសួងលេខ ២៦៥ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យចំណូល សម្រាប់ឆ្នាំ ២០២២ នៅក្រសួងពាណិជ្ជកម្ម ៤៥៥០


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


២៩-១២-២០២១ -ប្រកាសលេខ ៥៤៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហេន 7 ហ្គាម៉ិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤៥៥៣

២៩-១២-២០២១ -ប្រកាសលេខ ៥៤៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ិដស៍ ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរ ប៉ាក់សម្លៀកបំពាក់ និងផលិតម៉ាស់ ៤៥៥៦

២៩-១២-២០២១ -ប្រកាសលេខ ៥៤៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤៥៥៩

២៩-១២-២០២១ -ប្រកាសលេខ ៥៤៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយ អេស (ខេមបូឌា) កែកឃីង ប្រូដាក់ ឯ.ក បង្កើតរោងចក្រ ផលិតសម្ភារវេចខ្ចប់គ្រប់ប្រភេទ ៤៥៦២

២៩-១២-២០២១ -ប្រកាសលេខ ៥៤៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យី ដា មេនូហ្វេកធឺរី ខូ អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ បោកគក់ ប៉ាក់ និងបោះពុម្ព ៤៥៦៥

២៩-១២-២០២១ -ប្រកាសលេខ ៥៤៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៉ៃ ហុង ខេមបូ ឯ.ក បង្កើតរោងចក្រ ផលិតអំពូលភ្លើងលំអ ខ្សែភ្លើង និងកេសកាតុង ៤៥៦៨

២៩-១២-២០២១ -ប្រកាសលេខ ៥៤៩ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខាត ថាយអឺរ ឯ.ក បង្កើតរោងចក្រ ផលិតសំបកកង់យានយន្ត ៤៥៧១

៣០-១២-២០២១ -ប្រកាសលេខ ៥៥១ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សិន តៃ ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៤៥៧៤

២២-៣-២០២២ -ប្រកាសលេខ ១២៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វិនសេដ ហ្គាមេន & វ៉ូលែន ណៃធីង ហ្វាកធើរី បង្កើតរោងចក្រ កាត់ដេរ និងចាក់សម្លៀកបំពាក់ ៤៥៧៧

៤-៧-២០២២ -ប្រកាសលេខ ២៥៨ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ុងហេងស៊ីង លេឌើរ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ៤៥៨០

## ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

២៧-៧-២០២១ -ប្រកាសលេខ ០៧៤២ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៧៤២ រថ.អប្រក.លអ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២១ ៤៥៨៣

## ៤~ទីស្ដីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

២៩-៦-២០២២ -ប្រកាសលេខ ០៩៣ កយ.ប្រក/២២ ស្ដីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សបន្ត ៤៥៨៧

៤-៧-២០២២ -ប្រកាសលេខ ០៩៤ កយ.ប្រក/២២ ស្ដីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ៤៥៨៩

## ៥~ទីស្ដីការរដ្ឋមន្ត្រីក្រសួងការពារជាតិ

១២-៧-២០២២ -សេចក្ដីសម្រេចលេខ ០២៨ សសរ.កពជ ស្ដីពី ការតែងតាំង និងផ្លាស់ប្ដូរសមាសភាព លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួងការពារជាតិ ៤៥៩១

# ព្រះរាជក្រម

## យើង

នស/រកម/០៨២២/ ០១០

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភា លើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ



## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ សម្រាប់ជាចំណូលថវិកាជាតិ ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសង្គតិភាព ដោយកំណត់ក្របខ័ណ្ឌច្បាប់ ស្ថាប័នជាគោលយន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ សំដៅចូលរួមចំណែកបម្រើឧត្តមប្រយោជន៍នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ច្បាប់នេះជាច្បាប់គោលមានវិសាលភាពអនុវត្តចំពោះចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលអនុវត្តដោយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងភាគីឯកជនពាក់ព័ន្ធ ដែលស្ថិតក្រោមអធិបតេយ្យភាព និង/ឬយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យកំណត់ក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២

## ចំណូលមិនមែនសារពើពន្ធ

### ផ្នែកទី១

### ប្រភេទចំណូលមិនមែនសារពើពន្ធ

**មាត្រា៤ .-**

ចំណូលមិនមែនសារពើពន្ធ ត្រូវបានបែងចែក ដូចខាងក្រោម៖

១- ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

២- ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត។

៣- ចំណូលពីសេវាសាធារណៈ។

៤- ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម។

៥- ចំណូលមិនមែនសារពើពន្ធដទៃទៀត ដូចមានកំណត់ក្នុងមាត្រា ៣៣ នៃច្បាប់នេះ។

ចំណូលមិនមែនសារពើពន្ធ ដែលជាប្រភេទចំណូលថ្មី ក្រៅពីប្រភេទចំណូលមិនមែនសារពើពន្ធខាងលើ ត្រូវកំណត់ដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

## ផ្នែកទី២
## ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៥ .-**

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ មានជាអាទិ៍៖

១- ចំណូលពីការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

២- ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ។

៣- ចំណូលពីសម្បទានសេវាសាធារណៈ។

៤- ចំណូលពីធនធានធម្មជាតិ។

៥- ចំណូលផ្សេងៗទៀតដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ។

**មាត្រា៦ .-**

ចំណូលពីការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាចំណូលដែលទទួលបានមកពីការលក់ ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាចលនទ្រព្យនិងអចលនទ្រព្យ។

ការលក់ ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវអនុវត្តតាមវិធាននិងនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៧ .-**

ចំណូលពីការលក់ ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាចលនទ្រព្យ មានជាអាទិ៍៖

- ការលក់ឯកសារ ឬលតាបត្រ ឬលិខិតបោះពុម្ពផ្សេងៗ
- ផលបានពីការលក់ទ្រព្យសម្បត្តិកម្មេចកម្ទី សត្វពាហនៈ
- ការលក់ផលិតផលកសិកម្ម
- ផលបានពីការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យ
- ការលក់ចលនទ្រព្យ ដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដទៃទៀត។

**មាត្រា៨ .-**

ចំណូលពីការលក់ឬការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាអចលនទ្រព្យ មានជាអាទិ៍៖

- ចំណូលពីការលក់ដី ឬប្រាក់លម្អៀងពីការដោះដូរដី និង/ឬសំណង់អគារ
- ផលបានពីការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជាអចលនទ្រព្យដទៃទៀត។

**មាត្រា៩ .-**

ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ជាចំណូលដែលទទួលបានមកពីថ្លៃជួល ភាគចំណែករបស់រដ្ឋ និងការបែងចែកផលចំណេញ ដូចមានចែងក្នុងកិច្ចសន្យាឬកិច្ចព្រមព្រៀងនៃការជួលទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យនិង/ឬអចលនទ្រព្យ មានជាអាទិ៍៖

- ការជួលដីនិងអគារ
- ការជួលអគារឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ
- ការជួលសម្ភារៈបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ
- ការជួលទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យនិងអចលនទ្រព្យដទៃទៀត។

ការជួលទ្រព្យសម្បត្តិរដ្ឋ ត្រូវអនុវត្តតាមវិធាននិងនីតិវិធី ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១០ .-**

ចំណូលពីការជួលដីនិងអគារ ជាចំណូលដែលទទួលបានមកពីការជួលដីទំនេររបស់រដ្ឋឬការជួលដីមានអគារ ដែលជាការជួលដីនិងអគារទាំងមូលរបស់រដ្ឋ។

**មាត្រា១១ .-**

ចំណូលពីការជួលអគារឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជាចំណូលដែលទទួលបានមកពីការជួលផ្នែកនៃអគារឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ មានជាអាទិ៍ ការជួលការិយាល័យ ការជួលអាហារដ្ឋាន ការជួលកន្លែងផ្សព្វផ្សាយ ការជួលកន្លែងលក់ដូរ ឬការជួលសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

**មាត្រា១២ .-**

ចំណូលពីការជួលសម្ភារៈបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ ជាចំណូលដែលទទួលបានមកពីការជួលសម្ភារៈ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្ររបស់រដ្ឋ មានជាអាទិ៍ បរិក្ខារបច្ចេកទេសនិងឧស្សាហកម្ម យានយន្ត ម៉ាស៊ីនស្ទូច ត្រាក់ទ័រ។

**មាត្រា១៣ .-**

ចំណូលពីសម្បទានសេវាសាធារណៈ ចែកចេញជាចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ ដែលមានដូចខាងក្រោម៖

**ក. ចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន** ជាចំណូលដែលទទួលបានមកពីគម្រោងវិនិយោគ ដូចមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬការផ្គត់ផ្គង់សេវាសាធារណៈ មានជាអាទិ៍៖

- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈបម្រើដល់វិស័យដឹកជញ្ជូននិងវិស័យភស្តុភារកម្ម មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ចំណតសាធារណៈ ព្រែកជីក
- ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍និងទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល
- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី បំពង់បង្ហូរប្រេងនិងឧស្ម័ន និងសេវាសាធារណៈផ្សេងទៀត ក្នុងវិស័យរ៉ែនិងថាមពល
- ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក ប្រព័ន្ធប្រមូលស្តារប្រព្រឹត្តិកម្មទឹកកខ្វក់ ការគ្រប់គ្រងសំណល់ និងសេវាសាធារណៈផ្សេងទៀតបម្រើឱ្យកិច្ចគាំពារបរិស្ថាន
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យទេសចរណ៍ វិស័យវប្បធម៌និងសិល្បៈ វិស័យកីឡា និងលំនៅឋានសង្គម
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានជាអាទិ៍ តំបន់សេដ្ឋកិច្ចពិសេស សួនបណ្តុំឧស្សាហកម្មធុនតូចនិងមធ្យម សួនបច្ចេកវិទ្យានិងនវានុវត្តន៍
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងសេវាមន្ទីរពិសោធន៍ ការគាំទ្រការកែច្នៃ ការរក្សាផលិតផល និងការជំរុញពាណិជ្ជកម្ម
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យកសិកម្មនិងប្រព័ន្ធធារាសាស្ត្រ
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈផ្សេងទៀតដែលច្បាប់ដោយឡែកអនុញ្ញាត។

វៀរលែងតែមានកំណត់នៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ចំណូលពីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន មានរូបភាពជាភាគចំណែករបស់រដ្ឋដែលគិតជាភាគរយនៃចំណូលដុលតាមការព្រមព្រៀងរវាងភាគីរដ្ឋនិងភាគីឯកជន។

ការគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ត្រូវអនុវត្តតាមវិធាននិងនីតិវិធី ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ខ.ចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ** ជាចំណូលទទួលបានមកពីការប្រគល់សិទ្ធិជូនបុគ្គលឯកជន ដើម្បីធ្វើអាជីវកម្មលើទ្រព្យសម្បត្តិរដ្ឋ ឬសេវាសាធារណៈដែលពុំមែនជាសេវាអធិបតេយ្យរបស់រដ្ឋ តាមរយៈលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងគោលដៅបម្រើសេវាសាធារណៈជូនដល់សាធារណជន ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ដែលមានជាអាទិ៍ ផ្សារ កំពង់ចម្លង ចំណតយានជំនិះ ចំណតជលយាន មជ្ឈមណ្ឌលបែងចែកផលនេសាទ សត្តឃាតដ្ឋាន អនាម័យសត្វ ទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ស្ថានីយផ្ទេរសំរាមសំណល់រឹងទីប្រជុំជន សេវាអនាម័យ ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ វៀរលែងតែសេវាសាធារណៈដែលមានកំណត់ក្នុងចំណុច ក ខាងលើ។ ចំណូលនេះ ត្រូវបានកំណត់ក្នុងទម្រង់ជាការបែងចែកផល ដែលរដ្ឋទទួលបានចំណូលអាស្រ័យទៅតាមកំណើនអាជីវកម្មរបស់បុគ្គលឯកជន។

ការគ្រប់គ្រងសម្បទានគ្រប់គ្រងសេវាសាធារណៈ ត្រូវអនុវត្តតាមវិធាននិងនីតិវិធី ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៤ .–**

ចំណូលពីសម្បទានគ្រប់គ្រងសេវាសាធារណៈ ត្រូវបានបែងចែកជាប្រភេទចំណូល មានជាអាទិ៍ ៖

- ចំណូលពីចំណតយានជំនិះ ជាចំណូលដែលទទួលបានមកពីការផ្តល់សិទ្ធិរបស់រដ្ឋលើការធ្វើអាជីវកម្មចំណតយានជំនិះគ្រប់ប្រភេទ ដូចជា រថយន្ត ម៉ូតូ កង់ជាដើម ជូនដល់បុគ្គលឯកជន
- ចំណូលពីចំណតជលយាន ជាចំណូលដែលទទួលបានមកពីការផ្តល់សិទ្ធិរបស់រដ្ឋលើការធ្វើអាជីវកម្មទូក កាណូត កប៉ាល់ ការប្រើប្រាស់កំពង់ផែ ចំណតជើងទឹក ជូនដល់បុគ្គលឯកជន
- ចំណូលពីសត្តឃាតដ្ឋាន ជាចំណូលទទួលបានមកពីកន្លែងធ្វើអាជីវកម្មពិឃាដសត្វនៅតាមសត្តឃាតដ្ឋាន
- ចំណូលពីការជួលកន្លែងលក់ដូរក្នុងផ្សារ ជាចំណូលដែលទទួលបានមកពីការជួលតូប រាន ស្តង់ កន្លែងលក់ដូរក្នុងផ្សារដទៃទៀត
- ចំណូលពីកំពង់ចម្លង ជាចំណូលដែលទទួលបានមកពីការបម្រើសេវាកម្មចម្លងអ្នកធ្វើដំណើរ សត្វពាហនៈ សម្ភារៈ និងយានយន្តគ្រប់ប្រភេទ នៅតាមកំពង់ដ ដទទឹង ដបណ្តោយដែលរដ្ឋបានកំណត់
- ចំណូលពីមជ្ឈមណ្ឌលបែងចែកផលនេសាទ ជាចំណូលដែលទទួលបានមកពីអាជីវកម្មដែលធ្វើការប្រមូលផ្តុំ និងបែងចែកការប្រើប្រាស់ផលនេសាទដែលរដ្ឋបានកំណត់
- ចំណូលពីភាស៊ីផ្សារ ជាចំណូលដែលទទួលបានមកពីការប្រមូលពីអាជីវករលក់ដូរក្នុងនិងក្រៅផ្សារដែលរដ្ឋបានកំណត់
- ចំណូលពីអនាម័យសត្វ ជាចំណូលដែលទទួលបានមកពីការត្រួតពិនិត្យសុខភាពសត្វនៅសត្តឃាតដ្ឋាន ឬបានមកពីការត្រួតពិនិត្យអនាម័យសត្វតាមការដឹកជញ្ជូន នាំចេញ នាំចូល
- ចំណូលពីទីលានទុកដាក់សំរាម និងចំណូលពីស្ថានីយផ្ទេរសំរាមជាចំណូលដែលទទួលបានមកពីការផ្តល់កន្លែងទុកដាក់ កន្លែងផ្ទេរ និងការទាញយកធនធាន ឬប្រព្រឹត្តិកម្មសំរាម សំណល់រឹងទីប្រជុំជនសម្រាប់បុគ្គលដែលប្រើប្រាស់ទីតាំង
- ចំណូលពីសេវាអនាម័យ ជាចំណូលដែលទទួលបានមកពីកម្រៃសេវាប្រមូលសំរាមតាមលំនៅឋាន និងអាជីវកម្មដ្ឋានផ្សេងៗ
- ចំណូលពីសម្បទានដទៃទៀតរបស់រដ្ឋ ដែលពាក់ព័ន្ធនឹងសេវាសាធារណៈ។

**មាត្រា១៥ .-**

ចំណូលពីធនធានធម្មជាតិ ជាចំណូលដែលទទួលបានមកពីការចាត់ចែងលើធនធានធម្មជាតិ មានជាអាទិ៍ សម្បទានរ៉ែ ចំណូលពីប្រេងកាត សម្បទានដីសេដ្ឋកិច្ច ផលព្រៃឈើ អនុផលព្រៃឈើ ផលពីនេសាទ ធនធានកម្រ និងធនធានធម្មជាតិដទៃទៀត តាមរយៈលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងទម្រង់ជាកម្រៃសួយសារ ឬការបង់ថ្លៃឈ្នួល ឬបុព្វលាភ ឬភាគចំណែករបស់រដ្ឋ ឬការបែងចែកផល ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៦ .-**

ចំណូលពីធនធានធម្មជាតិ ត្រូវបានបែងចែកជាប្រភេទចំណូល មានជាអាទិ៍៖

- ផលពីព្រៃឈើ មានជាអាទិ៍ ចំណូលពីការលក់ឈើឈរ សួយសារ បុព្វលាភ ផលព្រៃឈើ អនុផលព្រៃឈើ
- ចំណូលពីប្រេងកាត មានជាអាទិ៍ ចំណូលបានមកពីការធ្វើអាជីវកម្មប្រេងកាតដោយរដ្ឋ ថ្លៃឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត ចំណូលពីសួយសារប្រេងកាត ចំណូលពីចំណែកផលប្រេងកាតរបស់រដ្ឋ ប្រាក់រង្វាន់ចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រេងកាត
- ចំណូលពីសម្បទានរ៉ែ មានជាអាទិ៍ ចំណូលបានមកពីថ្លៃឈ្នួលផ្ទៃក្រឡាសម្រាប់ដំណាក់កាលស្វែងរុករករ៉ែនិងដំណាក់កាលធ្វើអាជីវកម្មធនធានរ៉ែ ចំណូលទទួលបានពីសួយសារផលិតផលរ៉ែ ភាគចំណែករបស់រដ្ឋពីការធ្វើអាជីវកម្មធនធានរ៉ែ
- ចំណូលពីសម្បទានដីសេដ្ឋកិច្ច ជាចំណូលបានមកពីកិច្ចសន្យានិងកិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ច
- ផលពីនេសាទ ជាចំណូលបានមកពីការជួលឡូតិ៍នេសាទ
- ចំណូលពីធនធានកម្រ មានជាអាទិ៍ ចំណូលបានមកពីហ្វ្រេកង់ស៍វិទ្យុ
- ចំណូលបានមកពីការប្រើប្រាស់សេវាប្រព័ន្ធអេកូឡូស៊ី
- ចំណូលបានមកពីធនធានធម្មជាតិដទៃទៀត។

**មាត្រា១៧ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣

## ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត

**មាត្រា១៨ .-**

ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត រួមមាន ចំណូលដែលទទួលបានមកពីការបង់៖

- [illegible]គលាភឬអតិរេកសាច់ប្រាក់
- [illegible]លើសនៃទុនទំនេរ
- [illegible]សាច់ប្រាក់ និងសមមូលសាច់ប្រាក់ក្រោយពីសហគ្រាសនិងអង្គភាពត្រូវបានរំលាយ។

**មាត្រា១៩ .-**

ការបង់ភាគលាភឬអតិរេកសាច់ប្រាក់ និងភាគលើសនៃទុនទំនេរ ត្រូវអនុវត្តតាមបែបបទនិងនីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត។

**មាត្រា២០ .-**

ក្នុងករណីដែលច្បាប់ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្កើតសហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ពុំបានចែងអំពីការកំណត់បែងចែកភាគលាភតាមអត្រាកំណត់គិតជាភាគរយនៃប្រាក់ចំណេញសុទ្ធឬអតិរេកទេនោះ និងវៀរលែងតែមានការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល សហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ត្រូវមានកាតព្វកិច្ចបង់ភាគលាភឬអតិរេកសាច់ប្រាក់ ចូលថវិការដ្ឋយ៉ាងតិចចំនួន ១០% (ដប់ភាគរយ) នៃប្រាក់ចំណេញសុទ្ធឬអតិរេកសាច់ប្រាក់ បន្ទាប់ពីក្រុមប្រឹក្សាភិបាលឬគណៈគ្រប់គ្រងបានពិនិត្យនិងអនុម័តលើតុល្យការនិងគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**មាត្រា២១ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិសម្រេចក្នុងការកំណត់ឱ្យសហគ្រាសសាធារណៈនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ធ្វើការបង់មួយចំណែក ឬទាំងអស់ នូវភាគលើសនៃទុនទំនេរ ចូលថវិកាជាតិ ក្នុងករណីពិនិត្យឃើញថា សហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុណាដែលពុំមានតម្រូវការចាំបាច់សម្រាប់វិនិយោគឬអភិវឌ្ឍសហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុរបស់ខ្លួន។

**មាត្រា២២ .-**

វៀរលែងតែមានបដិប្បញ្ញត្តិដែលចែងដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរំលាយសហគ្រាសសាធារណៈ ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិចឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត សមមូលសាច់ប្រាក់ដែលជាចំណែករបស់ភាគីរដ្ឋ ត្រូវបង្វែរចូលគណនីទោលរតនាគារ។ រីឯទ្រព្យសកម្មដែលជាចលនទ្រព្យនិងអចលនទ្រព្យ ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ក្រោយពីបានធ្វើការជម្រះបញ្ជីតាមនីតិវិធីជាធរមាន និងស្របតាមលក្ខន្តិកៈរបស់សហគ្រាសឬរបស់ក្រុមហ៊ុន ឬការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀតនោះ។

**មាត្រា២៣ .-**

សហគ្រាសសាធារណៈ ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលយឺតយ៉ាវឬខកខានក្នុងការបង់ចំណូលចូលថវិការដ្ឋ ដូចមានចែងក្នុងផ្នែកទី៣នៃជំពូកទី២នៃច្បាប់នេះ ត្រូវចាត់ទុកជាបំណុលមិនមែនសារពើពន្ធ ដូចមានកំណត់ក្នុងជំពូកទី៥នៃច្បាប់នេះ។

## ផ្នែកទី៤
## ចំណូលពីសេវាសាធារណៈ

**មាត្រា២៤ .-**

ចំណូលពីសេវាសាធារណៈ ជាចំណូលដែលប្រមូលបានមកពីការបង់កម្រៃនៃការប្រើប្រាស់សេវាសាធារណៈដោយរូបវន្តបុគ្គល ឬនីតិបុគ្គលសម្រាប់សេវាបង់ថ្លៃរបស់រដ្ឋ។ ការផ្តល់សេវាសាធារណៈនិងការប្រមូលចំណូលពីសេវាសាធារណៈ ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅបម្រើផលប្រយោជន៍ទូទៅ។ កម្រៃសេវាសាធារណៈ ជាកម្មវត្ថុដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២៥ .-**

សេវាសាធារណៈដែលផ្តល់ដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំជាកម្រងសេវាសាធារណៈ និងផ្សព្វផ្សាយជាសាធារណៈដោយមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា ឬតម្លៃអតិបរមានៃសេវា រយៈពេលអតិបរមា នៃការផ្តល់សេវា និងសុពលភាពនៃសេវាទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

**មាត្រា២៦ .-**

សេវាសាធារណៈ អាចត្រូវបានផ្តល់ដោយភាគីឯកជន តាមរយៈកិច្ចសន្យាដែលធ្វើឡើងរវាងភាគីឯកជននិងក្រសួង ស្ថាប័នឬរវាងភាគីឯកជននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៧ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងនិងចាត់ចែងចំណូលពីសេវាសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៥
## ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម

**មាត្រា២៨ .-**

វៀរលែងតែការពិន័យនិងការដាក់ទណ្ឌកម្មពាក់ព័ន្ធនឹងចំណូលសារពើពន្ធ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម មានជាអាទិ៍ ចំណូលពីការផាកពិន័យ ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ ចំណូលពីការរឹបអូស ផលពីការពិន័យផ្សេងៗ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**មាត្រា២៩ .-**

ចំណូលពីការផាកពិន័យ ជាចំណូលមិនមែនសារពើពន្ធ ដែលប្រមូលបានមកពីការពិន័យអន្តរការណ៍ចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ការពិន័យជាប្រាក់ចំពោះការមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធនានា រួមទាំងការប្រាក់លើទឹកប្រាក់ផាកពិន័យ ដែលអនុវត្តដោយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៣០ .-**

ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ ជាចំណូលមិនមែនសារពើពន្ធដែលប្រមូលបានតាមរយៈសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣១ .-**

ចំណូលពីការរឹបអូស មានជាអាទិ៍៖

- ចំណូលពីការរឹបអូសប្រាក់កក់ ជាចំណូលដែលទទួលបានមកពីការរឹបអូសប្រាក់កក់នៃការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ ជាចំណូលដែលទទួលបានមកពីការរឹបអូសទ្រព្យសម្បត្តិជាហិរញ្ញវត្ថុពីបទល្មើសនិងពីការចាត់ចែងទ្រព្យសម្បត្តិរឹបអូសជាចលនទ្រព្យនិងអចលនទ្រព្យពីបទល្មើស មានជាអាទិ៍ បទល្មើសគ្រឿងញៀន បទល្មើសព្រៃឈើ បទល្មើសដទៃទៀត។

**មាត្រា៣២ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ផ្នែកទី៦
## ចំណូលមិនមែនសារពើពន្ធដទៃទៀត

**មាត្រា៣៣ .-**

ចំណូលមិនមែនសារពើពន្ធដទៃទៀត ជាចំណូលដែលទទួលបានជាអាទិ៍មកពី៖

១-ទ្រព្យនិទាឃាទ។

២-ទ្រព្យគ្មានម្ចាស់គ្រប់គ្រង។

៣-ប្រទានកម្ម។

៤-អច្ច័យទាន។

៥-វិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

៦-វិស័យល្បែងពាណិជ្ជកម្ម។

៧-ផលហិរញ្ញវត្ថុ។

៨-ផលផ្សេងៗ និងផលពិសេសដទៃទៀត។

៩-មូលនិធិទៅតាមវិស័យពាក់ព័ន្ធ។

**មាត្រា៣៤ .-**

ចំណូលពីទ្រព្យនិទាឃាទ ជាចំណូលទទួលបានមកពីការចាត់ចែងទ្រព្យដែលពុំមានសន្តតិជនដែលត្រូវក្លាយមកជាទ្រព្យសម្បត្តិរដ្ឋ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣៥ .-**

ចំណូលពីទ្រព្យគ្មានម្ចាស់គ្រប់គ្រង ជាចំណូលទទួលបានមកពីការចាត់ចែងទ្រព្យដែលក្លាយមកជាទ្រព្យសម្បត្តិរដ្ឋដោយហេតុផលទ្រព្យនោះពុំមានម្ចាស់គ្រប់គ្រង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣៦ .-**

ចំណូលពីប្រទានកម្ម ជាចំណូលដែលទទួលបានមកក្រោមទម្រង់ជាអំណោយជាហិរញ្ញវត្ថុ និងចំណូលពីការចាត់ចែងទ្រព្យជាចលនទ្រព្យឬអចលនទ្រព្យ ដែលទទួលបានពីប្រទានកម្មសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**មាត្រា៣៧ .-**

អច្ច័យទាន ជាចំណូលដែលទទួលបានមកក្រោមទម្រង់ជាអំណោយជាហិរញ្ញវត្ថុដែលទទួលតាមរយៈមតកសាសន៍ និងចំណូលពីការចាត់ចែងទ្រព្យជាចលនទ្រព្យឬអចលនទ្រព្យ ដែលទទួលបានតាមរយៈមតកសាសន៍ ដោយអនុលោម តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**មាត្រា៣៨ .-**

ចំណូលពីវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាចំណូលដែលទទួលបានជាអាទិ៍មកពី វិស័យធានារ៉ាប់រង និងសោធនឯកជន វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម វិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ក្រៅពីចំណូលដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៣៩ .-**

ចំណូលពីវិស័យល្បែងពាណិជ្ជកម្ម ជាចំណូលដែលបានមកពីល្បែងកាស៊ីណូ ល្បែងភ្នាល់ ល្បែងផ្សងសំណាង និងល្បែងពាណិជ្ជកម្មដទៃទៀត ក្រៅពីចំណូលដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤០ .-**

ផលហិរញ្ញវត្ថុ ជាចំណូលដែលបានមកពីការយកអតិរេកសាច់ប្រាក់បណ្ដោះអាសន្នទៅវិនិយោគលើមូលបត្រអាចជួញដូរបាន អត្រាការប្រាក់លើបំណុល និងកម្រៃផ្សេងទៀតដែលបានមកពីប្រតិបត្តិការហិរញ្ញវត្ថុ។

**មាត្រា៤១ .-**

ផលផ្សេងៗនិងផលពិសេស ជាចំណូលដែលទទួលបានមកពីការបង់អតិរេកថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ចំណូលពីការបង់អតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែល ទឹកប្រាក់បង្វិលចូលថវិការដ្ឋ ដោយការបើកផ្ដល់លើសសម្រាប់ការអនុវត្តគម្រោង និងផល ឬចំណូលផ្សេងៗទៀត ដែលត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៤២ .-**

មូលនិធិទៅតាមវិស័យពាក់ព័ន្ធ ជាចំណូលមិនមែនសារពើពន្ធដែលប្រមូលបានពីការបង់ប្រាក់ពីវិស័យឯកជន និងសាធារណៈ ផ្អែកតាមកាតព្វកិច្ច ឬតាមគោលការណ៍ស្ម័គ្រចិត្ត ដែលមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៤៣ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពីទ្រព្យនិទាឃាទ ទ្រព្យគ្មានម្ចាស់ ប្រទានកម្ម អច្ច័យទាន វិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ វិស័យល្បែងពាណិជ្ជកម្ម ផលហិរញ្ញវត្ថុ និងផលផ្សេងៗនិងផលពិសេស ត្រូវកំណត់ដោយអនុក្រឹត្យ។

វិធាននិងនីតិវិធីនៃការគ្រប់គ្រងនិងការប្រើប្រាស់មូលនិធិតាមវិស័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី។

## ផ្នែកទី៧
## លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ

**មាត្រា៤៤ .-**

រាល់ការបង្កើត ការកែប្រែ ឬការរំលាយលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬការផ្ទេរមួយផ្នែក ឬទាំងស្រុងនូវសិទ្ធិនិងកាតព្វកិច្ច ដូចមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវទទួលការពិនិត្យនិងឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបង្កើត ការកែប្រែ ឬការរំលាយលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬការផ្ទេរមួយផ្នែក ឬទាំងស្រុងនូវសិទ្ធិនិងកាតព្វកិច្ច ដូចមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងករណីមិនបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជាមោឃៈ។

លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវតម្កល់ទុកនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការចុះហត្ថលេខាលើលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធនានាទៅឱ្យតំណាងឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយអនុលោមតាមវិធាននិងនីតិវិធីជាធរមាន។

**មាត្រា៤៥ .-**

លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងការជួលទ្រព្យសម្បត្តិរដ្ឋ សម្បទានធនធានធម្មជាតិ និងសម្បទានសេវាសាធារណៈ ក្រោមរូបភាពជាគម្រោងវិនិយោគ គម្រោងសម្បទាន និងគម្រោងអភិវឌ្ឍន៍ អាចជាកម្មវត្ថុនៃការបង្កើតសិទ្ធិដល់អ្នកជួល ឬសម្បទានិក ឬវិនិយោគិន ឬអ្នកអភិវឌ្ឍ ក្នុងការផ្ទេរមួយផ្នែក ឬទាំងស្រុងនូវសិទ្ធិនិងកាតព្វកិច្ច ដូចមានកំណត់ក្នុងលិខិតគតិយុត្តនោះទៅឱ្យតតិយជន ក្នុងរយៈពេលមិនលើសពីរយៈពេលដែលមានកំណត់ក្នុងលិខិតគតិយុត្តទាំងនោះ បន្ទាប់ពីមានការពិនិត្យនិងឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបង់កម្រៃនៃការផ្ទេរសិទ្ធិលើលិខិតគតិយុត្ត ឬកម្រៃនៃការផ្ទេរគម្រោង ចូលថវិកាជាតិ។

វិធាននិងនីតិវិធីលម្អិត និងការកំណត់កម្រៃនៃការផ្ទេរមួយផ្នែកឬទាំងស្រុង នូវសិទ្ធិនិងកាតព្វកិច្ច ដូចមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤៦ .-**

ភាគីរដ្ឋ មានសិទ្ធិរំលាយលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធមុនពេលកំណត់ ក្នុងករណីណាមួយដូចខាងក្រោម៖

១-ខកខានក្នុងការបង់ចំណូលជូនរដ្ឋគ្រប់ចំនួនក្រោយឥណប្រតិទានយ៉ាងយូរបំផុត ១៨០ ថ្ងៃ ក្នុងករណីមិនមានប្រធានសក្តិកើតមានឡើង។

២-ប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

៣-តម្រូវការក្នុងការបម្រើប្រយោជន៍សាធារណៈ តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

៤-រូបវន្តបុគ្គលឬនីតិបុគ្គល ត្រូវបានប្រកាសក្ស័យធនឬអសាធនភាព ដោយអនុលោមតាមច្បាប់ជាធរមាន។

លក្ខខណ្ឌដូចមានចែងក្នុងមាត្រានេះ ជាវិធានអប្បបរមាដែលភាគីអាចព្រមព្រៀងកំណត់នូវលក្ខខណ្ឌបន្ថែមក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៣
## ស្ថាប័នមានសមត្ថកិច្ច
### ផ្នែកទី១
### ស្ថាប័នមានសមត្ថកិច្ចថ្នាក់ជាតិ

**មាត្រា៤៧ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការជូនរាជរដ្ឋាភិបាលលើរាល់ប្រតិបត្តិការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ រួមបញ្ចូលទាំងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងចាត់វិធានការតឹងទារបំណុលមិនមែនសារពើពន្ធទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា។ ក្នុងការបំពេញមុខងារនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- រៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង ការតាមដាន និងការត្រួតពិនិត្យការប្រមូលចំណូលមិនមែនសារពើពន្ធ
- បង្កើតនិងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ផ្សព្វផ្សាយ ណែនាំ និងជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ

- ជំរុញការកៀរគរ ការកត់ត្រា និងការត្រួតពិនិត្យចំណូលមិនមែនសារពើពន្ធគ្រប់មុខសញ្ញាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ដឹកនាំការតឹងទារនិងការដោះស្រាយបំណុលមិនមែនសារពើពន្ធ
- គ្រប់គ្រង តាមដាន និងត្រួតពិនិត្យការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ត្រួតពិនិត្យនិងវាយតម្លៃភាពត្រឹមត្រូវនៃរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ អនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ និងលើកសំណើដំណោះស្រាយលើបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងគណនេយ្យភាពនិងបូរណភាពនៃការរៀបចំរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច
- ពិនិត្យនិងសម្រេចលើការកែសម្រួលចំណូលមិនមែនសារពើពន្ធ ឬលើកសំណើជូននាយករដ្ឋមន្ត្រី ពិនិត្យនិងសម្រេច
- រៀបចំសំណើវិធានការលើកទឹកចិត្តឬសំណើវិធានការរឹតត្បិត ពាក់ព័ន្ធនឹងការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច
- ត្រួតពិនិត្យនិងធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការប្រមូលចំណូលមិនមែនសារពើពន្ធ របស់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ
- ដឹកនាំដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយរាយការណ៍ជូននាយករដ្ឋមន្ត្រី។

**មាត្រា៤៨ .-**

ក្រសួង ស្ថាប័នដែលប្រមូលចំណូលមិនមែនសារពើពន្ធ បំពេញភារកិច្ចក្នុងការគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធ ដូចតទៅ៖

- រៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ សម្រាប់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ដឹកនាំនិងគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន
- អនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន
- កៀរគរ កត់ត្រាចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដែលប្រមូលបាន
- ចាត់វិធានការលើបំណុលមិនមែនសារពើពន្ធ ដែលត្រូវតឹងទារ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន និងស្នើសុំវិធានការដោះស្រាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីពុំអាចដោះស្រាយបាន។

**មាត្រា៤៩ .-**

ក្រសួង ស្ថាប័នដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង្កើតគណៈកម្មការ អនុគណៈកម្មការ ឬក្រុមការងារតាមការចាំបាច់ ដើម្បីបំពេញមុខងារជាសេនាធិការ ក្នុងការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធឱ្យក្រសួង ស្ថាប័នសាមី ដែលប្រមូលចំណូលមិនមែនសារពើពន្ធនីមួយៗ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការ អនុគណៈកម្មការ ឬក្រុមការងារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែក។

## ផ្នែកទី២
## ស្ថាប័នមានសមត្ថកិច្ចថ្នាក់ក្រោមជាតិ

**មាត្រា៥០ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធ នៅថ្នាក់ក្រោមជាតិដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ក្នុងការបំពេញមុខងារនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំសម្រាប់ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ដឹកនាំនិងគ្រប់គ្រងការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនៃរាជធានី ខេត្ត
- ជំរុញការកៀរគរនិងការកត់ត្រានូវគ្រប់មុខសញ្ញាចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនៃរាជធានី ខេត្ត
- ចូលរួមដឹកនាំតឹងទារបំណុលមិនមែនសារពើពន្ធ នៅរាជធានី ខេត្ត
- រៀបចំនិងបូកសរុបរបាយការណ៍ស្ដីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនៃរាជធានី ខេត្ត
- ពិនិត្យនិងសម្រេចលើរបាយការណ៍ស្ដីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនៃរាជធានី ខេត្ត ដើម្បីបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន និងស្នើសុំវិធានការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីពុំអាចដោះស្រាយបាន។

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ជាតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥១ .-**

ក្នុងករណីចាំបាច់ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចបង្កើតគណៈកម្មការ ឬក្រុមការងារ ជាសេនាធិការ ដើម្បីពង្រឹងនិងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ និងការតឹងទារបំណុលមិនមែនសារពើពន្ធ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការឬក្រុមការងារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ផ្នែកទី៣
## កិច្ចសហការអន្តរស្ថាប័ន

**មាត្រា៥២ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

- ផ្ដល់ឯកសារ ព័ត៌មាន និងទិន្នន័យទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តចំណូលមិនមែនសារពើពន្ធ

- រៀបចំផែនការយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ
- គ្រោង កៀរគរ ប្រមូល បង់ និងបែងចែកចំណូលមិនមែនសារពើពន្ធ
- តឹងទារបំណុលមិនមែនសារពើពន្ធ
- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តការប្រមូលចំណូល
- ពិនិត្យលទ្ធភាពស្វែងរកប្រភពចំណូលមិនមែនសារពើពន្ធថ្មី
- សើរើនិងកំណត់តម្លៃនៃគ្រប់ប្រភេទចំណូលមិនមែនសារពើពន្ធក្នុងករណីចាំបាច់ ស្របទៅតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច ទីផ្សារ និងសង្គមនៃព្រះរាជាណាចក្រកម្ពុជា។

វិធាននិងនីតិវិធីនៃការសើរើនិងការកំណត់តម្លៃតាមប្រភេទចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី៤
## ការប្រមូលចំណូលមិនមែនសារពើពន្ធ

### ផ្នែកទី១
### ការរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធ

**មាត្រា៥៣ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធនៃសាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាចំណូលថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**មាត្រា៥៤ .-**

វិធាននិងនីតិវិធីនៃការរៀបចំគម្រោងចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ។

### ផ្នែកទី២
### ការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ

**មាត្រា៥៥ .-**

ចំណូលមិនមែនសារពើពន្ធត្រូវបានប្រមូល ដើម្បីជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

ការបែងចែកចំណូលមិនមែនសារពើពន្ធ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៥៦ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលមានកំណត់ជាអាទិ៍ ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ប្រកាសអន្តរក្រសួងពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈនិងការពិន័យជាប្រាក់ សេចក្តីសម្រេចស្ថាពររបស់ស្ថាប័នតុលាការ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត ដោយត្រូវធ្វើការកត់ត្រា តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រមូលចំណូលដោយអនុលោមតាមវិធាននិងនីតិវិធី ដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៥៧ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង់ចំណូលដែលប្រមូលបានចូលថវិកាជាតិ ទៅតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន ដោយមិនអនុញ្ញាតឱ្យដកចំណូលនេះ ទៅកាត់កងដោយត្រង់ជាមួយចំណាយ ឬរក្សាទុកសាច់ប្រាក់ ឬមូលប្បទានបត្រនៅក្នុងបេឡាដ្ឋទេយ្យករចំណូល លើសពីចំនួនដែលបានអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬនាយករដ្ឋមន្ត្រី និង/ឬដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានឡើយ។

**មាត្រា៥៨ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង់ចំណូលមិនមែនសារពើពន្ធដែលប្រមូល ឬទទួលបាន ចូលថវិកាជាតិដោយគោរពតាមគោលការណ៍ ដូចខាងក្រោម៖

- បង់ចូលគណនីទោលរបស់រតនាគារឬធនាគារដៃគូ
- បង់តាមរយៈរដ្ឋទេយ្យករចំណូលឬភ្នាក់ងារប្រមូលចំណូល។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំសលាកបត្របង់ចំណូលថវិកា ដែលជាសក្ខីបត្រមូលដ្ឋាននៃការបង់ចំណូលរបស់ខ្លួនសម្រាប់គណនេយ្យករសាធារណៈ ដោយអនុលោមតាមវិធាននិងនីតិវិធី ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និង/ឬដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៩ .-**

វិធាននិងនីតិវិធីនៃការប្រមូលចំណូលនិងការបង់ចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣
## ការកត់ត្រា ការតាមដាន និងការធ្វើរបាយការណ៍

**មាត្រា៦០ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំបូកសរុបរបាយការណ៍ស្ដីពីការអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធ នៅគ្រប់អង្គភាពក្រោមឱវាទរបស់សាមីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមវិធាននិងនីតិវិធីដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៦១ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការកត់ត្រាតាមដានស្ដីពីការអនុវត្តការប្រមូលចំណូល និងធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្ដីពីស្ថានភាពនៃការអនុវត្តការប្រមូលចំណូល ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានទៀងទាត់ ដោយអនុលោមតាមកាលបរិច្ឆេទ និងនីតិវិធីដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវទទួលខុសត្រូវលើការចំពោះការធ្វើបែបបទលិខិតយុត្តិការ និងកាន់កាប់បញ្ជិកាគណនេយ្យនូវរាល់ប្រតិបត្តិការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

វិធាននិងនីតិវិធីនៃការកត់ត្រា ការតាមដាន និងការធ្វើរបាយការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦២ .-**

នៅរៀងរាល់ដំណាច់ឆ្នាំ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការបូកសរុប និងផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្តការប្រមូលចំណូលប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងធ្វើរបាយការណ៍វិភាគលទ្ធផលនៃការអនុវត្តការប្រមូលចំណូលប្រចាំឆ្នាំនោះ ដោយអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

វិធាននិងនីតិវិធីនៃការធ្វើរបាយការណ៍វិភាគលទ្ធផលនៃការអនុវត្តការប្រមូលចំណូលប្រចាំឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៣ .-**

របាយការណ៍វិភាគលទ្ធផលនៃការអនុវត្តការប្រមូលចំណូលប្រចាំឆ្នាំ ត្រូវធ្វើជាមូលដ្ឋាននៃកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

## ផ្នែកទី៤
## ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

**មាត្រា៦៤ .-**

ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធទាំងក្នុងនិងក្រៅប្រទេសដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ជាកម្មវត្ថុនៃការធ្វើទំនើបកម្មតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីពង្រឹងយន្តការប្រមូល កត់ត្រា និងតាមដានចំណូលនិងបំណុលមិនមែនសារពើពន្ធ ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព និងគណនេយ្យភាព។

**មាត្រា៦៥ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាស្ថាប័ននិម្មាបនករ ក្នុងការបង្កើត ការគ្រប់គ្រប់គ្រង និងការដឹកនាំអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

**មាត្រា៦៦ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវចូលរួមអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឱ្យបានពេញលេញគ្រប់ជ្រុងជ្រោយ ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំបង្កើតលេខអត្តសញ្ញាណចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដោយលម្អិតតាមមុខចំណូលនីមួយៗ តាមការណែនាំ ការពិនិត្យ និងការសម្រេចអំពីអនុលោមភាព ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៧ .-**

រាល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតឡើងដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាអំពីការធ្វើសន្ទានកម្មកម្មវិធីរួម ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៦៨ .-**

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី៥
## បំណុលមិនមែនសារពើពន្ធ

**មាត្រា៦៩ .-**

បំណុលមិនមែនសារពើពន្ធ ជាចំនួនទឹកប្រាក់ នៃចំណូលមិនមែនសារពើពន្ធ ដែលបុគ្គលជាប់កាតព្វកិច្ចត្រូវបង់ខកខានក្នុងការបំពេញកាតព្វកិច្ចបង់ចំណូល ក្នុងរយៈពេលនិងលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬបង្កាន់ដៃបង់ប្រាក់ពិន័យ ឬសេចក្ដីសម្រេចរបស់តុលាការមានសមត្ថកិច្ច ឬច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

សមាសភាគនៃបំណុលមិនមែនសារពើពន្ធ មានជាអាទិ៍ ចំនួនទឹកប្រាក់ដែលបុគ្គលជាប់កាតព្វកិច្ចត្រូវបង់ ខកខានក្នុងការបំពេញកាតព្វកិច្ចបង់ចំណូល ការប្រាក់ ប្រាក់ពិន័យ។

**មាត្រា៧០ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវត្រួតពិនិត្យតាមដានជាប្រចាំ លើកាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលមានកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ។

ក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចត្រូវបង់មិនបានអនុវត្តកាតព្វកិច្ចបង់ចំណូលរបស់ខ្លួននៅឥណប្រតិទានដែលមានចែងក្នុងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវចាត់ទុកជាបំណុលមិនមែនសារពើពន្ធ និងត្រូវចាត់វិធានការលើបំណុលមិនមែនសារពើពន្ធ។

**មាត្រា៧១ .-**

ក្នុងករណីដែលបំណុលមិនមែនសារពើពន្ធ មិនអាចប្រមូលបានដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ បំណុលនោះត្រូវអនុវត្តវិធានការតឹងទារ តាមរយៈយន្តការក្រុមការងារអន្តរក្រសួងតឹងទារបំណុលមិនមែនសារពើពន្ធដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧២ .-**

បំណុលមិនមែនសារពើពន្ធ អាចជាកម្មវត្ថុនៃការជម្រះបញ្ជី ក្នុងករណីដូចខាងក្រោម៖

- កូនបំណុលជានីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានប្រកាសក្ស័យធន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- កូនបំណុលត្រូវបានពិនិត្យនិងវាយតម្លៃអំពីអសាធនភាព ដោយក្រុមការងារអន្តរក្រសួងតឹងទារបំណុលមិនមែនសារពើពន្ធ
- កូនបំណុលបាត់ខ្លួន ឬអវត្តមាន ឬទទួលមរណភាពដោយគ្មានសិទ្ធិវន្តឬសន្តតិជន ដោយមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច

- កូនបំណុលបានទូទាត់សងនូវបំណុលដែលជំពាក់គ្រប់ចំនួន និងចប់សព្វគ្រប់
- បំណុលដែលបាត់សាវតារនិងត្រូវបានវាយតម្លៃដោយក្រុមការងារអន្តរក្រសួងតឹងទារបំណុលមិនមែនសារពើពន្ធ
- បំណុលដែលត្រូវបានកំណត់ជាកម្មវត្ថុនៃការជម្រះបញ្ជីដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬដោយការសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៧៣ .-**

ការជម្រះបញ្ជីបំណុលមិនមែនសារពើពន្ធ ពុំមានអានុភាពគតិយុត្តធ្វើឱ្យថ្លោះសិទ្ធិរបស់រដ្ឋ ក្នុងការតឹងទារបំណុលមិនមែនសារពើពន្ធឡើយ ក្នុងករណីពិនិត្យឃើញថា៖

- កូនបំណុលដែលបានបញ្ជាក់អសាធនភាព មានសាធនភាពឡើងវិញ ឬ
- កូនបំណុលដែលបានបាត់ខ្លួន ឬអវត្តមាន បានបង្ហាញខ្លួន ឬមានវត្តមានវិញ ឬ
- កូនបំណុលដែលបានបញ្ជាក់ថាគ្មានសិទ្ធិវន្ត ឬគ្មានសន្តតិជន ត្រូវបានរកឃើញថាមានសិទ្ធិវន្តឬមានសន្តតិជនវិញ។

**មាត្រា៧៤ .-**

វិធាននិងនីតិវិធីនៃការតឹងទារ និងការជម្រះបញ្ជីនៃបំណុលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦

## ការដោះស្រាយវិវាទ

**មាត្រា៧៥ .-**

វៀរលែងតែមានកំណត់នៅក្នុងច្បាប់ឬលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធដទៃទៀត ក្នុងករណីមិនពេញចិត្តទៅនឹងការកំណត់តម្លៃ និង/ឬកិច្ចប្រតិបត្តិការនៃការប្រមូលចំណូលមិនមែនសារពើពន្ធដែលខុសទិសដៅ ឬផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាននោះ បុគ្គលដែលទទួលសេវាសាធារណៈ និងបុគ្គលដែលជាភាគីនៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ មានសិទ្ធិប្ដឹងតវ៉ាដោយត្រង់ទៅប្រធានស្ថាប័ននៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ឬតាមរយៈយន្តការដែលក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្កើតសម្រាប់ទទួលពាក្យបណ្ដឹង និងដោះស្រាយវិវាទពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ឬប្ដឹងតវ៉ាទៅក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា៧៦ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចបង្កើតក្រុមការងារឬគណៈកម្មការអន្តរក្រសួង ស្ថាប័ន ដើម្បីរៀបចំយន្តការដោះស្រាយវិវាទពាក់ព័ន្ធនឹងការកំណត់តម្លៃ និង/ឬកិច្ចប្រតិបត្តិការនៃការប្រមូលចំណូលមិនមែនសារពើពន្ធ។

**មាត្រា៧៧ .-**

វិធាននិងនីតិវិធីនៃការទទួល ការពិនិត្យ និងការដោះស្រាយវិវាទ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត [illegible]។

## ជំពូកទី៧
## អធិការកិច្ចនិងសវនកម្ម

**មាត្រា៧៨ ._**

ការអនុវត្តការប្រមូលចំណូលនិងការតឹងទារបំណុលមិនមែនសារពើពន្ធ ព្រមទាំងការលើកទឹកចិត្តនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវទទួលរងអធិការកិច្ចហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬអធិការកិច្ច និង/ឬសវនកម្មដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧៩ ._**

| ៣៦ | លោក | ឡូន សេដា | វរមន្ត្រី ថ្នាក់លេខ ២ | ០២/០៥/២០២២ |
| ៣៧ | លោក | ស្វាយ សាវ៉ាត | វរមន្ត្រី ថ្នាក់លេខ ២ | ០៤/០៤/២០២២ |

| ១៦-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | | | | |
|---|---|---|---|---|
| ៣៨ | លោក | **បាន មុនីរដ្ឋ** | វរមន្ត្រី ថ្នាក់លេខ ១ | ០៣/០៣/២០២២ |
| ៣៩ | លោក | **ម៉ៅ សុថា** | វរមន្ត្រី ថ្នាក់លេខ ១ | ០១/០៦/២០២២ |
| ៤០ | លោក | **ជា ស៊ីថា** | វរមន្ត្រី ថ្នាក់លេខ ២ | ១០/០៦/២០២២ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ២ កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** : ៣៥៨.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរ ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ប្រគល់ភារកិច្ចជូនលោក **ឌួច សុថារិទ្ធ** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ២ កើត ខែ ជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:.៣៥៩.អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១ .-** តែងតាំងលោក **ឆាន ម្ញរ័ត្ន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ២ កើត ខែ ជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៣៦០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការលុបឈ្មោះ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** លុបឈ្មោះ នាយទាហាន ចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ចំពោះ វរសេនីយ៍ឯក **ឈឹម សុធារ៉ា** អត្តលេខ ១៦៣៤៣៥ នាយលេខាធិការដ្ឋាន អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ២ កើត ខែ ជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៦១.អនក្រ.តត.

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន **១៧** រូប នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ របស់ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- លោក **សុខ ធីរៈ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ២- លោក **ខួន វណ្ណារី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៣- លោក **អ៊ុក ឥន្ទ្រា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៤- លោក **គុល គន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៥- លោក **ម៉ននី បណ្ឌិត** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៦- លោកស្រី **សុខ ចាន់សយ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |

| | | |
|---|---|---|
| ៧- លោក **ខ៊ា សំណាង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៨- លោក **ឃិត សុធារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៩- លោក **រាម សុមេធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១០- លោក **គិន តក្តី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១១- លោក **នង ចន្ថា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១២- លោកស្រី **ឌុយ សុគន្ធតក្រ្កា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ១៣- លោក **យស ស៊ីណាត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ១៤- លោកស្រី **ចាន់ តញ្ញា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ១៥- លោក **សរ សុជានី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ១៦- លោក **អ៊ូត ឈាងលី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៧- លោក **ចន ទី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ២ កើត ខែ ជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៦២.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន ១៣ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោក | **ហឿ ប៊ុណ្ណាឧត្តម** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២-លោក | **ឈឿន ស៊ីណារ៉ូ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៣-លោកស្រី | **ជា សុជាតា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤-លោក | **ម៉ៅ ចំរើន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |

| | | | |
|---|---|---|---|
| ៥-លោក | **មៀច មាករ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦-លោកស្រី | **ស្រ៊ុន ច័ន្ទរស្មី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧-លោក | **ចំរើន មិត្តសិរ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨-លោក | **ឆាន ណារិទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩-លោក | **ហោខ សៃឡា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០-លោក | **ឃិម វណ្ណា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១១-លោក | **ឃិន រ៉ាឌី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១២-លោក | **កប សាមុទ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៣-លោក | **គីម ថារ៉ូ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |

**មាត្រា ២ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការចំនួន ០៩ រូប នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោក | **សោម សុតក្រា** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ២-លោក | **អ៊ឹម ណារ៉េត** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៣-លោក | **ញ៉ៀម សុវណ្ណា** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៤-លោកស្រី | **នេត ចណ្ណា** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥-លោក | **ឈុន សុខសាន្ត** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦-លោក | **រ៉ែន ណារ៉ូ** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | |
| ៧-លោកស្រី | **ឃី សុគន្ធា** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ថ្នាក់លេខ ១<br>មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | |
| ៨-លោក | **ទ្រី សំអាត** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ថ្នាក់លេខ ១<br>មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | |
| ៩-លោក | **ផែន សុតារដ្ឋ** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ថ្នាក់លេខ ១<br>មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | |

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ២ កើត ខែ ជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកែសម្រួលប្រភេទ និងតម្លៃសេវាសាធារណៈ ដែលស្ថិតក្នុងកម្រងសេវាសាធារណៈ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលប្រភេទ និងតម្លៃសេវាសាធារណៈ ក្នុងចំណុចទី1 នៃ "គ3. ផលិតផលមានដើមកំណើតពីសត្វ សម្រាប់ប្រើក្នុងផ្នែកផ្សេងៗ ដែលមិនអាចបរិភោគបាន" នៃកម្រងសេវាសាធារណៈភ្ជាប់នឹងប្រកាសរួមលេខ ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចខាងក្រោម÷

- ប្រភេទសេវាចាស់

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1 | ស្បែកស្រស់ប្រឡាក់អំបិល ឬ ស្ងួត (គ.ក្រ) | | | |
| | ចរាចរក្នុងផ្ទៃប្រទេស | 10 | 1-2 ថ្ងៃ | តាមការស្នើ |
| | ចរាចរនាំចេញ | 100 | 1-2 ថ្ងៃ | តាមការស្នើ |
| | ចរាចរនាំចូល | 200 | 1-2 ថ្ងៃ | តាមការស្នើ |
| | ចរាចរឆ្លងកាត់ប្រទេស | 100 | 1-2 ថ្ងៃ | តាមការស្នើ |

- ប្រភេទសេវាចាស់ខាងលើ ត្រូវបានលុបចោល និងកែសម្រួលថ្មី ដូចតទៅ ÷

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1 | ស្បែកស្រស់ប្រឡាក់អំបិល ឬ ស្ងួត | | | |
| | + ចរាចរក្នុងផ្ទៃប្រទេស | មិនយកកម្រៃ | ១-២ថ្ងៃ | តាមការស្នើ |
| | + ចរាចរនាំចេញ ឬនាំឆ្លងកាត់ | | | |
| | - បរិមាណត្រឹម ១០តោនចុះ | ១០០.០០០ | ១-២ថ្ងៃ | តាមការស្នើ |
| | - បរិមាណលើសពី ១០តោន ដល់ត្រឹម ៥០តោន | ១៥០.០០០ | ១-២ថ្ងៃ | តាមការស្នើ |
| | - បរិមាណលើសពី ៥០តោន ដល់ត្រឹម ១០០តោន | ២០០.០០០ | ១-២ថ្ងៃ | តាមការស្នើ |
| | - បរិមាណលើសពី ១០០តោន ដល់ត្រឹម ៥០០តោន | ៥០០.០០០ | ១-២ថ្ងៃ | តាមការស្នើ |
| | - បរិមាណលើសពី ៥០០តោនឡើង | ១.០០០/តោន | ១-២ថ្ងៃ | តាមការស្នើ |
| | + ចរាចរនាំចូល | | | |
| | - បរិមាណត្រឹម ១០តោនចុះ | ២០០.០០០ | ១-២ថ្ងៃ | តាមការស្នើ |
| | - បរិមាណលើសពី ១០តោន ដល់ត្រឹម ៥០តោន | ៣០០.០០០ | ១-២ថ្ងៃ | តាមការស្នើ |
| | - បរិមាណលើសពី ៥០តោន ដល់ត្រឹម ១០០តោន | ៤០០.០០០ | ១-២ថ្ងៃ | តាមការស្នើ |
| | - បរិមាណលើសពី ១០០តោន ដល់ត្រឹម ៥០០តោន | ១.០០០.០០០ | ១-២ថ្ងៃ | តាមការស្នើ |
| | - បរិមាណលើសពី ៥០០តោនឡើង | ២.០០០/តោន | ១-២ថ្ងៃ | តាមការស្នើ |

**ប្រការ២ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែមេសា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៦៩៤១....សហវ...ប្រក

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតវិទ្យាល័យចំណោល

## នៅក្រសួងទេសចរណ៍

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទៈ (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ២៥៣ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ៧៧២ សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៩៤០ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាជាតិ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២២
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យករចំណូលនៅក្រសួងទេសចរណ៍ ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូល ដែលត្រូវបង្កើតរជ្ជទេយ្យចំណូលឆ្នាំ២០២២ មានដូចខាងក្រោម÷

| | | |
|---|---|---|
| ១-អនុគណនី ៧៣០៦៦ | ចំណូលអជ្ញាបណ្ណក្នុងស្រុក | ចំនួនទឹកប្រាក់ ១ ៧០៩ ០០០ ០០០រៀល |
| ២-អនុគណនី ៧៣០៨៧ | ចំណូលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | ចំនួនទឹកប្រាក់ ៣៨ ០០០ ០០០រៀល |
| ៣-អនុគណនី ៧៤០១២ | ចំណូលពីការផាកពិន័យ និងទោសទណ្ឌកម្ម | ចំនួនទឹកប្រាក់ ២០ ០០០ ០០០រៀល |
| | | **សរុបទឹកប្រាក់ ១ ៧៦៧ ០០០ ០០០រៀល** |

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន ២ ០០០ ០០០រៀល (ពីរលានរៀលគត់)

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិកាដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ប្រតិភូរាជរដ្ឋាភិបាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ និងអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ ប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍

ថោង ខុន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ពក

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការបង្កើតរដ្ឋលេខាធិការយ្យចំណូលសម្រាប់ឆ្នាំ២០២២**
**នៅក្រសួងពាណិជ្ជកម្ម**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/សន/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២២
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២៥៣ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យចំណូលនៅក្រសួងពាណិជ្ជកម្ម ដើម្បីប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

បញ្ជីរាយប្រភេទចំណូល ដែលត្រូវបង្កើតរជ្ជទេយ្យចំណូលឆ្នាំ២០២២មានដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. អនុគណនី ៧៣០០៨ (ផលទុនផ្សេងៗទៀត) | ចំនួនទឹកប្រាក់ | ៤ ៥៧៨ ០០០ ០០០៛ |
| ២. អនុគណនី ៧៣០១២ (លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ) | ចំនួនទឹកប្រាក់ | ២ ៤៦០ ០០០ ០០០៛ |
| ៣. អនុគណនី ៧៣០២៣ (ផលពីការបង្កើតសហគ្រាស) | ចំនួនទឹកប្រាក់ | ១១ ២០០ ០០០ ០០០៛ |
| ៤. អនុគណនី ៧៣០៤៨ (ផលពីសេវាផ្សេងៗទៀត) | ចំនួនទឹកប្រាក់ | ១ ៨៣៤ ០០០ ០០០៛ |
| ៥. អនុគណនី ៧៣០៦៥ (ចំណូលពីអាជ្ញាប័ណ្ណនាំចេញ) | ចំនួនទឹកប្រាក់ | ៣៥ ០០០ ០០០៛ |
| ៦. អនុគណនី ៧៣០៦៧ (កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ) | ចំនួនទឹកប្រាក់ | ២៦ ៩២៥ ០០០ ០០០៛ |
| ៧. អនុគណនី ៧៣០៨៧ (ផលពីការត្រួតពិនិត្យគុណភាពផលិតផលនិងការគោរពបទដ្ឋាន) | ចំនួនទឹកប្រាក់ | ១០០ ០០០ ០០០៛ |
| ៨. អនុគណនី ៧៤០១២ (ការពិន័យនិងការដាក់ទណ្ឌកម្មពិន័យជាប្រាក់) | ចំនួនទឹកប្រាក់ | ២ ២០០ ០០០ ០០០៛ |
| | **សរុបទឹកប្រាក់** | **៤៩ ៣៣២ ០០០ ០០០៛** |

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមាដែលអនុញ្ញាតទុកក្នុងបេឡាមានកំណត់ត្រឹមចំនួន ២.០០០.០០០៛ (ពីរលានរៀលគត់)។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

ប្រការ៤.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង ក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ[illegible] ស័ក ព.ស.២៥៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

*កន្លែងទទួល:*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ៤៤៣ ឧវបន.អក.ប្រកា

ថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៩៧៤/១៨ គ.វ.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ហេន 7 ហ្គាម៉ិន ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ហេន 7 ហ្គាម៉ិន ឯ.ក (**HAND 7 GARMENT CO., LTD.**) តំណាងដោយលោក **CHUANG, SHEN-PEP** សញ្ជាតិចិន(អ៊ីតាលី) កាន់លិខិតឆ្លងដែនលេខ **353387015** ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅសួនឧស្សាហកម្មវឌ្ឍនៈ២ ផ្លូវជាតិលេខ៣ អគារលេខ២០ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។
ស្លាកឈ្មោះរោងចក្រ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ ហេន 7 ហ្គាម៉ិន ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ១៦៥ ឧស.កឧ.ប្រក.០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌដង្កោ
- រដ្ឋបាលសង្កាត់ក្រាំងពង្រ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៥៤៤ ...........................

ថ្ងៃ.......................... ខែ.................. ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៥៥១/០៩ គ.វ.ក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការវិនិយោគលើគំរោងបង្កើតរោងចក្រកាត់ដេរ និងប៉ាក់សម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់ក្រុមហ៊ុន ស៊ីដស៍ ហ្គាមេន (ខេមបូឌា)

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ីដស៍ ហ្គាមេន (ខេមបូឌា) (SEEDS GARMENT (CAMBODIA) CO., LTD.)** តំណាងដោយលោកស្រី **LAU, MUN CHEE ANGELA** សញ្ជាតិចិន(ហុងកុង) កាន់លិខិតឆ្លងដែនលេខ **KJ0616507** ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ បង្កើតរោងចក្រកាត់ដេរ ប៉ាក់សម្លៀកបំពាក់ និងផលិតម៉ាស់ ដែលមានទីតាំងស្ថិតនៅសួនឧស្សាហកម្មវឌ្ឍនៈ១ ផ្លូវចោមចៅ អគារលេខ១ ភូមិដំណាក់ធំ២ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ១-សម្លៀកបំពាក់ (កាត់ដេរ) | ១៤១០ |
| ២-សម្លៀកបំពាក់ (ប៉ាក់) និងម៉ាស់ | ១៣៩៩ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរ ប៉ាក់សម្លៀកបំពាក់ និងផលិតម៉ាស់ ស៊ិងស៍ ហ្គាមេន (ខេមបូឌា)** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ១៥០ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតសង្កាត់គោកឃ្លាងនៃខណ្ឌសែនសុខ រាជធានីភ្នំពេញ
- យោងលិខិតលេខ២៤៤/០៥ គ.វ.ក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រុមហ៊ុន សិន តៃ ហ្គាមេន (ខេមបូឌា)

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន សិន តៃ ហ្គាមេន (ខេមបូឌា) **(ZHEN TAI GARMENT (CAMBODIA) CO., LTD.)** តំណាងដោយលោក **YANG, CHUNAN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខEA5469980 ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ សិន តៃ ហ្គាមេន (ខេមបូឌា)** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ២៧៦ ឧស.ក.ឧ.ប្រក.០៦ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌសែនសុខ
-រដ្ឋបាលសង្កាត់គោកឃ្លាង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុគា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខៈ ...........................

ថ្ងៃ........................ ខែ............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៤៨៣/០៩ គ.វ.ក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការវិនិយោគលើគំរោងបង្កើតរោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ របស់ក្រុមហ៊ុន វីនសេដ ហ្គាមេន & វូលែន ណែធីង ហ្វាកធើរី

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន វីនសេដ ហ្គាមេន & វូលែន ណែធីង ហ្វាកធើរី (WINSAND GARMENT & WOOLEN KNITTING FACTORY CO., LTD.) តំណាងដោយលោក CHENG SU CHEONG សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ MA0158924 ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣ បង្កើតរោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅផ្លូវលេខ១១៨A ភូមិព្រៃគគួច ឃុំព្រែកផ្លាប់ ស្រុកលើកដែក ខេត្តកណ្តាល។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| ១-សម្លៀកបំពាក់ (កាត់ដេរ) | ១៤១០ |
| ២-សម្លៀកបំពាក់ (ចាក់) | ១៤៣០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ វិនសេដ ហ្គាមេន & វូលែន ណែជីង ហ្វាកធើរី "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ១៣៤ ឧស.ក៦.ប្រក.០៤ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តកណ្តាល
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល
- រដ្ឋបាលស្រុកលើកដែក
- រដ្ឋបាលឃុំព្រែកដាច់
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ..................... ថ្ងៃ.................. ខែ.................. ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០៤...... ខែ.......... ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៤៥៩៨/១៧ គ.វ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ របស់ក្រុមហ៊ុន យ៉ុងហេងស៊ីង លេឌើរ (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **យ៉ុងហេងស៊ីង លេឌើរ (ខេមបូឌា)** ឯ.ក **(YONGHENGXING LEATHER (CAMBODIA) CO., LTD.)** តំណាងដោយលោក **XU, YANHUA** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ**EB0166167** ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ បង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅសួនឧស្សាហកម្ម វ៉ាយសេវេន (ភូមិជ្រៃ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ)។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| កាបូបគ្រប់ប្រភេទ | ១៥១២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតកាបូបគ្រប់ប្រភេទ យ៉ុងហេងស៊ីង លេឡើរ (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០៩៥ ឧស.កឧ.ប្រក.០៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**ហាន សុតា**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តកំពង់ស្ពឺ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
- -រដ្ឋបាលស្រុកសំរោងទង
- -រដ្ឋបាលឃុំត្រពាំងគង

"ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៧៨២ រដ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
## លេខ ០៧៨៧ រដ.អប្រក.លអ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ របស់លោក វ៉ាត់ វៀម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ ដែលមានស្លាកយីហោឈ្មោះ ដេប៉ូតេលា វៀម ម៉ូនីនាថ ស្ថិតនៅភូមិត្រសិត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ របស់លោក វ៉ាត់ វៀម (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានដាក់លក់ហ្គាសធុងក្បែរទូចាក់ឧស្ម័នឥន្ធនៈ

២. ចម្ងាយពីពោងឧស្ម័នឥន្ធនៈលើដីទៅរបងព្រំដីស្ថានីយត្រូវមានប្រវែងអប្បបរមា ៧.៥ ម៉ែត្រ ហើយមិនត្រូវស្ថិតនៅក្នុងរោងមានជញ្ជាំងបាំងជិត តែត្រូវនៅទីស្រឡះអាចឱ្យខ្យល់បក់ផាត់បានល្អ និងត្រូវមានរបងសំណាញ់ដែកព័ទ្ធជុំវិញការពារពីការប៉ះទង្គិចនានា

៣. ទូចាក់ឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីរបងព្រំដីស្ថានីយ
៤. ពោងប្រេងឥន្ធនៈមួយត្រូវដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៥. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំង ឬ របងការពារការប៉ះទង្គិចណាមួយ
៦. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រពីព្រំដីស្ថានីយ ក្នុងទីលម្ហ
៧. បំពង់ខ្យល់ប្រេងឥន្ធនៈមិនត្រូវមានបំពាក់វ៉ាន់បិទ បើក
៨. ទុយោចាក់ប្រេងឥន្ធនៈ មិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៩. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១០. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
១១. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១២. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.–.**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.–.**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៧៤២.ឧស.រជប្រក.លអរ......ចុះថ្ងៃទី.....២៧............ខែ.កក្កដា.......ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.–.**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៧៤២.ឧស.រជប្រក.លអរ ចុះថ្ងៃទី..២៧........ខែ.កក្កដា.........ឆ្នាំ២០២១....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.–.**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តត្បូងឃ្មុំ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ..៣រោច..ខែទុតិយាសាឍឆ្នាំឆ្លូវ..ត្រីស័ក.ព.ស.២៥៦៥.
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.២៧..ខែ.កក្កដា...ឆ្នាំ២០២១.

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តត្បូងឃ្មុំ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :០៩៣...កយ.ប្រក/២២

# ប្រកាស

## ស្តីពី

## ការដាក់មន្ត្រីរាជការ ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សបន្ត

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.តត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ១៨៩ កយ.ប្រក/២០ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- បានឃើញប្រកាសលេខ ១១៧ កយ.ប្រក/២១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សបន្ត
- យោងតាមពាក្យសុំរបស់សាមីខ្លួន

## សម្រេច

**ប្រការ១ .-**

ត្រូវបានអនុញ្ញាតលោកស្រី **គង់ គឹមលន់** អត្តលេខ ២៩២០៧០០២៣៤ ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មុខតំណែងជាមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅនាយកដ្ឋានសារការី នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍វិស័យយុត្តិធម៌ ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សបន្តរយៈពេល **៩ខែ** គិតចាប់ពី **ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។**

**ប្រការ២ .-**

សិទ្ធិទទួលប្រាក់បៀវត្ស ឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់ និងអតីតភាពការងារសម្រាប់សោធននិវត្តន៍របស់សាមីខ្លួន ត្រូវកាត់ផ្តាច់ក្នុងរយៈពេលដែលសាមីខ្លួនស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស។

**ប្រការ៣ .-**

សាមីខ្លួនត្រូវដាក់ពាក្យសុំចូលបម្រើការងាររបស់ខ្លួនវិញ ឲ្យបាន ២ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស នឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌរបស់ក្រសួង ក្នុងករណីដែលសាមីខ្លួនមិនចូលបម្រើការងារនៅថ្ងៃបញ្ចប់ភាពទំនេរគ្មានបៀវត្ស។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កើត រិទ្ធ

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០៨៤ គយ.ប្រក/២២

# ប្រកាស

## ស្តីពី

## ការដាក់មន្ត្រីរាជការ

## ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.តត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់ប្រធាននាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោស

## សម្រេច

**ប្រការ១ .-**

ត្រូវបានដាក់មន្ត្រីរាជការចំនួន **៣រូប** នៅនាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោស នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ រយៈពេល **៣ខែ** គិតចាប់ពី**ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** ដូចមានរាយនាមខាងក្រោម ៖

១. លោក **ភឹម សាន** អត្តលេខ ១៧៥០៥០០០០២ ឋានន្តរស័ក្តិ នាយក្រមការ ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីក្រមការ មុខតំណែងជាអនុប្រធានការិយាល័យកិច្ចការអយ្យការ និងវត្ថុតាង

២. លោកស្រី **លី សុខា** អត្តលេខ ២៨៦០៨០០១៥៨ ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មុខតំណែងជាអនុប្រធានការិយាល័យកិច្ចការអយ្យការ និងវត្ថុតាង

៣. លោក **ខាត់ ច័ន្ទណា** អត្តលេខ ១៧៩១២០០២០១ ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មុខតំណែងជាមន្ត្រីគ្រប់គ្រងរដ្ឋបាល។

**ប្រការ២ .-**

សិទ្ធិទទួលប្រាក់បៀវត្ស ឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់ និងអតីតភាពការងារសម្រាប់សោធននិវត្តន៍របស់សាមីខ្លួន ត្រូវកាត់ផ្តាច់ក្នុងរយៈពេលដែលសាមីខ្លួនស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស។

**ប្រការ៣ .-**

សាមីខ្លួនត្រូវទៅបង្ហាញខ្លួន និងចូលបម្រើការងារនៅអង្គភាពសាមីក្នុងអំឡុងពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស នឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌរបស់ក្រសួង ក្នុងករណីដែលសាមីខ្លួនមិនចូលបម្រើការងារនៅថ្ងៃបញ្ចប់ភាពទំនេរគ្មានបៀវត្ស។ សាមីខ្លួនអាចចូលបម្រើការងារក្នុងមុខតំណែងរបស់ខ្លួនវិញបាន ក្នុងករណីដែលកន្លែងនោះនៅទំនេរពុំទាន់មានមន្ត្រីមកជំនួស។

**ប្រការ៤ .-**

ប្រធានអង្គភាពសាមី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការដាក់ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ផ្ញើមកក្រសួងនៅថ្ងៃបញ្ចប់នៃភាពទំនេរគ្មានបៀវត្សនេះ។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**កើត រិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ០២៧៥ សសរ.ការ.

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំង និងផ្លាស់ប្តូរសមាសភាពលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ នៅក្នុងក្រសួងការពារជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩០៣ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧/ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញសេចក្តីសម្រេចលេខ ១៤៩ សសរ ចុះថ្ងៃ២៦ ខែសីហា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារសម្របសម្រួលការគ្រប់គ្រងគ្រោះមហន្តរាយ និងក្រុមការងារអន្តរាគមន៍ប្រតិបត្តិការរុករក និងសង្គ្រោះគ្រោះមហន្តរាយរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញសារាចរលេខ០២សរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតយន្តការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួង ស្ថាប័ន

- បានឃើញសេចក្តីសម្រេចលេខ០២៥ សសរ.កពជ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងការពារជាតិ ស្តីពីការបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួងការពារជាតិ
- យោងតាមសំណើរបស់ប្រធានលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួងការពារជាតិ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំង និងផ្លាស់ប្តូរសមាសភាពលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ នៅក្នុងក្រសួងការពារជាតិ ដូចខាងក្រោម ៖

១.ឧត្តមសេនីយ៍ឯក **ខឹមជា សាឃឿន** មេបញ្ជាការរង នាយសេនាធិការ កងទ័ពជើងគោក ជំនួសនាយឧត្តមសេនីយ៍ **ជា សារ៉ន** **អនុប្រធាន**

២.ឧត្តមសេនីយ៍ឯក **ហួត ឈាងអន** នាយរងសេនាធិការចម្រុះ អគ្គបញ្ជាការដ្ឋាន **សមាជិក** ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣.-**

អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន មេបញ្ជាការកងឯកភាព ដែលមានការពាក់ព័ន្ធ និងប្រធានលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១៤កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា ទៀ បាញ់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់
- ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី